**សេចក្តីប្រកាសព័ត៌មាន**

**ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦**

**គណៈកម្មាធិការទទួលបន្ទុកវិធានបទបញ្ជាផ្ទៃក្នុងរបស់**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC)**

**សូមចេញផ្សាយនូវសេចក្តីព្រាងនៃបទបញ្ជាផ្ទៃក្នុង**

នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ គណៈកម្មាធិការទទួលបន្ទុកវិធានបទបញ្ជាផ្ទៃក្នុងនឹងចេញផ្សាយនូវសេចក្តីព្រាងនៃវិធានបទបញ្ជាផ្ទៃក្នុង សំរាប់សាធារណៈជនផ្តល់មតិ។

គោលបំណងនៃវិធានបទបញ្ជាផ្ទៃក្នុងនេះ គឺដើម្បីពង្រឹងដល់នីតិវិធី សំរាប់ដំណើរការជម្រះក្តីនៅ ECCC នឹងដើម្បីអនុម័តនូវវិធានបន្ថែមសំរាប់បង្គ្រប់នូវចំនុចខ្វះខាតនៃនីតិវិធីមានស្រាប់ ដែលមិនអាច ដោះស្រាយបាន នូវបញ្ហាមួយចំនួនឬភាពខុសប្រក្រតីទាក់ទងដល់ការបកស្រាយឬការអនុវត្ត ឬ បញ្ហាចោទឡើងទាក់ទងនឹងអនុលោមភាពទៅនឹងបទដ្ឋានអន្តរជាតិ។ គណៈកម្មាធិការទទួលបន្ទុកវិធានបទបញ្ជាផ្ទៃក្នុង ត្រូវបានបង្កើតឡើងអំឡុងពេលសិក្ខាសាលាស្តីពីការរៀបចំផែនការ និងការអភិវឌ្ឍន៍យុត្តាធិការ ដែលបានធ្វើឡើងក្នុងដើមខែកក្កដា។ គណៈកម្មាធិការនេះ មានសមាសភាពចៅក្រមខ្មែរបីរូប និងចៅក្រមបរទេសពីររូប គឺមានជាអាទិ៍៖ លោក យូ ប៊ុនឡេង លោក ម៉ុង មុនីចរិយ៉ា ប្រាក់ គឹមសាន Agnieszka Klonowiecka-Milart និង Marcel Lemonde ហើយ
គណៈកម្មាធិការនេះមានការគាំទ្រពីលេខាធិការដ្ឋាននៅការិយាល័យរដ្ឋបាល និង អ្នកជំនាញការ បណ្ឌិត Gregory Stanton។ សមាជិករបស់គណៈកម្មាធិការនេះបានជួបប្រជុំ និងទំនាក់ទំនងគ្នាតាមអ៊ីម៉ែល ជាទៀងទាត់ចាប់តាំងពីខែកក្កដាមក។

នៅថ្ងៃទី២៣ខែតុលា អត្ថបទនៃសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានចែកជូនដល់សមា ជិកនៃកិច្ចប្រជុំពេញអង្គរបស់ចៅក្រម ព្រមទាំងសហព្រះរាជអាជ្ញា ប្រធានស្នាក្តី និងការិយាល័យ រដ្ឋបាល។ នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ ECCC និងចេញផ្សាយចែកជូនសាធារណៈជនជាបីភាសាគឺ ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។ បណ្តាអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអ្នកឯកទេសមួយចំនួនបានបញ្ចេញនូវចំណាប់អារម្មណ៍ដ៏មានតំលៃចំពោះបទបញ្ជាផ្ទៃក្នុងនេះ ហើយសេចក្តីព្រាងនេះកំពុងចែកជូនដល់អ្នកទាំងនោះ ព្រមទាំងមានផ្សព្វផ្សាយតាមបណ្តាញអ៊ីនធឺណែតផងដែរ (ចូរមើលអសយដ្ឋាន

នៃគេហទំពរ័ខាងក្រោម)។

យើងខ្ញុំ សូមស្វាគមន៍រាល់ការផ្តល់នូវអនុសាសន៍ និងទស្សនៈដ៏មានតំលៃលើសេចក្តីព្រាងវិធានបទបញ្ជាផ្ទៃក្នុងនេះក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់មកយើងនឹងចងក្រងនូវអនុសាសន៍ និងការបញ្ចេញ ទស្សនៈទាំងនោះ ហើយបញ្ជូនទៅកិច្ចប្រជុំពេញអង្គរបស់អង្គចៅក្រម ដែលត្រូវរៀបចំឡើងចាប់ពីថ្ងៃ ទី២០ ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៦។ កិច្ចប្រជុំពេញអង្គរបស់អង្គចៅក្រមនឹងពិភាក្សាលើសេចក្តីព្រាងនិងទស្សនៈរបស់សាធារណៈជន រួមគ្នាជាមួយសហព្រះរាជអាជ្ញា ប្រធានស្នាក្តី និងការិយាល័យរដ្ឋបាល ដើម្បីអនុម័ត្រយកមកប្រើប្រាស់ ជាផ្លូវការនៅECCC។

ចំពោះអត្ថបទទាំងមូលនៃសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង មានជាភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង សូមបើកមើលគេហទំព័រដូចខាងក្រោម៖

www.eccc.gov.kh

www.unakart-online.org/04 documents.htm

www.cambodia.gov.kh/krt

សូមបញ្ជូនការបញ្ចេញទស្សនៈរបស់លោកអ្នកអោយបានមុនថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦ រួចផ្ញើទៅជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលបន្ទុកវីធានផ្ទៃក្នុង តាមរយៈអាស័យដ្ឋាន: info@eccc.gov.kh និង boyle@un.org។

សំរាប់ព័ត៏មានបន្ថែម សូមទំនាក់ទំនង លោក **រាជ សម្បត្តិ** មន្រ្តីព័ត៏មាន តាមរយៈទូរសព្ទ័ (៨៥៥ (0)១២ ៤៨៨១៥៦) ឬ បណ្ឌិត Helen Jarvis ប្រធានកិច្ចការសាធារណ: តាមរយៈទូរសព្ទ័ (៨៥៥(0)១២៤៨៨១៣៤)។